# រឿង មហាចោរនៅទល់ដែន

**ភាគទី៧០ (ផែនការសម្ងាត់)**

លុះទៅដល់ផ្លូវតូចមួយដែលងងឹតស្លុង មានន្ទអែបខ្លួននឹងគល់ឈើមួយ តាគីរីអែបនៅគល់ឈើម្ខាងទៀត។

មានន្ទនិយាយតិចៗថា:

យើងចាំវានៅទីនេះហើយ! មិនយូរទេវាមកដល់ឥឡូវ!

អ្នកណា?

គឺអាពជានោះណ៎ា!

ឱ! អាដែលតែងនិយាយថា វាសងសឹកអោយបាននោះឬ? ពុ

បាទ! សងសឹកអាកាមា

អឺ! តានឹកឃើញហើយ វាថាវាសងសឹកដោយកាត់ដៃ កាត់ជើងអាកាមាមែនទេ?

បាទ! ដោយសម្លាប់ឪពុកខ្ញុំ!

តាគីរីព្រឺខ្នងខ្វាកៗ មានន្ទបន្តទៀតថា:

លោកតាងឿងឆ្ងល់អី ការពិតជាការពិត ឯការគ្រួសារជាការគ្រួសារ។ ឪពុកខ្ញុំជាឪពុក។ ព្រះកម្ពុត ជាព្រះកម្ពុត។ តែក្នុងពេលនេះយើងចាប់អាជាពឲ្យបាន ព្រះកម្ពុតត្រូវរស់មួយគ្រាសិន។ កុំទាន់អាលអោយគាត់ស្លាប់ ថាបើគាត់ស្លាប់ក្នុងពេលនេះមុខជាអំណាចបានទៅដៃអាកាមា និងអូនមណីមិនខាន។

សព្វថ្ងៃ ព្រះកម្ពុតមិនធ្វើឃោរឃៅខ្លាំងលើយើង បានជាអាកាមាចង់សម្លាប់ចោល។

ចៅដឹងរឿងទាំងនេះពីណាមក?

ខ្ញុំមានរនុកក្នុងមាំណាស់។ នៅជាមួយអូនមណី មានស្រីម្នាក់ឱ្យការខ្ញុំ។ ផែនការគេមានបីយ៉ាង ឥឡូវគេកំពុងសម្រេចផែនការទីពីររបស់គេ។

អ្នកណា?

អត្ថបទដោយ៖ មាស សុភាព

នាងមាលាកូនឧត្តុង្គ។

អូ! តាស្គាល់ហើយ

នុ៎ះលោកតា! វាចេញមកហើយ! ក្នុងគ្រានេះយើងកាន់ក័ព្វវាសនាជាតិ និងប្រជានុរាស្ត្រយើង។ លោកតាឃើញអាពជាទេ ដែលដើរមករកយើង។ បើយើងចាប់វាមិនបាន វាទៅធ្វើឃាតកម្មហើយ គឺស្អែកព្រឹកព្រះកម្ពុតត្រូវស្លាប់ រួចស្អែកអាកាមាឡើងកាន់អំណាច។ លោកតាឃើញទេ នោះហើយវាសនារាស្ត្រខ្មែរដែលកំពុងដើរ។ កាយវិការតែមួយរបស់យើងដែលមិនបានសម្រេច កម្ពុជាមុខជាផ្លាស់ទឹកមុខមិនខាន។

ដាពដើរមកដល់ មានន្ទផ្ទឹបខ្លួនទៅនឹងដើមឈើ តាគីរីញ៉ែរចុងដៃ មានន្ទស្ទុះក្វែតទៅទះស្មាដាព:

អ្ហេ! មិត្តនិយាយគ្នាពីរបីម៉ាត់សិន!

ដាពឈប់:

លោកគ្រូ! ឪ! ទៅណាមកណាទាំងយប់នេះ?

ចង់និយាយជាមួយដាពឯង នៅកន្លែងស្ងាត់ណាមួយ។

អត់ទោសលោកគ្រូ! យប់នេះខ្ញុំចង់និយាយតែជាមួយនឹងទេវតាប៉ុណ្ណោះឯង។

មានន្ទកៀកដៃដាពជាប់ តាគីរីដើរម្ខាង មានន្ទសើចសប្បាយផងនិយាយថា:

នែហ៎! ម៉េចដាពឯងមិនសុខចិត្តជជែកលេងបន្តិចជាមួយមិត្តភក្តិនោះ?

ដាពធ្វើសញ្ញាថាទទួលការ:នេះ ហើយជនទាំងបីដើរតម្រង់ទៅបន្ទប់ផ្ទះតៀមដែលមានន្ទជួល។

អង្គុយជុំវិញតុ ពីមុខពែងតែ មានន្ទនិយាយថា:

ទឹកនេះក្តៅៗ ឯចិត្តខ្ញុំកត់ក្តៅដូចទឹកតែ ព្រោះពេលនេះខ្ញុំបានឃើញមិត្តម្នាក់ គឺដាពនេះឯង។ ក្នុងជីវិតកំសត់របស់ខ្ញុំ ក្នុងពេលដែលយើងអស់សង្ឃឹមកាលខ្ញុំឃើញថា លើលោកនេះមានតែម្នាក់ឯងមួយ គឺដាពនេះហើយដែលខ្ញុំនឹកដល់។ ខ្ញុំដែលមិនចេះនឹកដល់។ ខ្ញុំដែលមិនចេះនឹកទោះឪពុកក្តីប្រពន្ធក្តី ខ្ញុំហាក់ដូចមានចិត្តចន្លោះតែមួយគឺនឹកដាពឯង។ ដាពឯងជឿទេ?

ដាពងក់ក្បាល:

អត្ថបទដោយៈ មាស សុភាព

ជឿណាស់លោកគ្រូ! បាទខ្ញុំជឿ ព្រោះគឺលោកគ្រូហើយដែលថ្ងៃនោះបានចង្អុលប្រាប់ផ្នូរខ្មោចម្ដាយខ្ញុំ។ តាំងពីថ្ងៃនោះមក វង់មុខលោកគ្រូស្ថិតនៅជានិច្ចក្នុងវិញ្ញាណខ្ញុំ។ ឥឡូវនេះ គឺយប់នេះមិនគួរណាឡើយខ្ញុំមកជួបលោកគ្រូទេ។ យប់នេះជាយប់ទីបំផុតនៃជីវិតខ្ញុំ ព្រោះវេលាដែលកល្បិយុគមួយយ៉ាងអស្ចារ្យជិតដើរមកដល់ហើយ ប្រហែលជាមានទេវតានាំផ្លូវលោកគ្រូដែលជាបុរសតែមួយដែលខ្ញុំស្រលាញ់មកឲ្យជួបនឹងខ្ញុំ មើលទៅ! លោកគ្រូ! ខ្ញុំចង់សងសឹកមនុស្សដែលសម្លាប់ម្ដាយខ្ញុំណាស់។

អឺ! មែន អាកាមាវាស្រលាញ់ម្ដាយជាពឯងមិនបានដូចចិត្តវាៗក៏សម្លាប់ទៅ អក័ព្វណាស់ជាពឯង មិនទាន់ដង្ហើមគាត់។ មានតែខ្ញុំដែលបានទទួលពាក្យបណ្ដាំរបស់គាត់មកជាពឯង។ ឥឡូវគាត់សម្រាកក្នុងសន្តិភាពហើយ។

ជាពខ្ទប់មុខយំឃ្សូរៗ មួយស្របក់ ទើបនិយាយថាៈ

លោកគ្រូ! នាំអោយខ្ញុំនឹករឿងមួយដែលខ្ញុំខាំធ្មេញជានិច្ច។ ស្អែកនេះ ម្ដាយខ្ញុំ បានខ្ញុំសងសឹកជួសហើយ!

ជាពសម្លាប់កាមា?

ទេ! ហាស់ៗទេ សម្លាប់ឪកាមា ដើម្បីឲ្យកាមាវេទនាតែលតោលម្នាក់ឯង ដូចខ្ញុំដែលតែលតោលមកហើយនេះ។

អ្នកណាអោយសម្លាប់?

**(សូមរង់ចាំតាមដានភាគទី៧១ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព